# សាស្ត្រានគរកាយ



៧៩៥.
១

ព.ស. ២៥៤៩ គ.ស ២០០៥

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

២៩៥.១

# ច្បាប់នគរកាយ



ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
១២៥៩/០៦

ព.ស.២៥៤៩ គ.ស.២០០៥

www.budinst.gov.kh www.elibraryofcambodia.org

# ឧស្សនៈកថា

ច្បាប់នគរកាយ បណ្ឌិត និងអ្នកប្រាជ្ញ សម័យមហានគរភ្នំ ដកស្រង់តាមឱវាទព្រះពុទ្ធបរមគ្រូជាអង្គម្ចាស់ មកចារតំកល់ទុកក្នុងសាស្ត្រាស្លឹករិតសំរាប់ថ្វាយព្រះមហាក្សត្រ និងប្រជានុរាស្ត្រ អ្នកកាន់ព្រះពុទ្ធសាសនារៀនសូត្រ ដើម្បីគ្រប់គ្រងព្រះនគរទាំងពារៈធមិ ទាំងអជ្ឈត្តិកធមិ ចាត់ទុកថាព្រះនគរដែនដីជាលោកិយធមិ រូបរាងកាយរបស់មនុស្សទាំងឡាយជា លោកុត្តរធមិបានគេចាត់ទុកថាជាច្បាប់នគរកាយ ដើម្បីអោយមនុស្សទាំងអស់គ្នាចេះរក្សាការពារកុំអោយអន្តរាយដូចជា ព្រះមហាក្សត្រចេះរក្សាការពារព្រះនគរប្រទេសរបស់ព្រះអង្គ បានគង់វង្សទាំងវប្បធមិ និងសេដ្ឋកិច្ច ប្រជានុរាស្ត្ររស់នៅប្រកបដោយសុភមង្គល និងសុខសន្តិភាព សម័យនេះប្រជានុរាស្ត្រអ្នកកាន់ព្រះពុទ្ធ សាសនា ព្រមទាំងព្រះមហាក្សត្រ បានរួបរួមសាមគ្គីគ្នាជាធ្លុងមួយដូចមានពាក្យថា ជាតិ សាសនា និងព្រះមហាក្សត្រ។ ប៉ុន្តែដល់ មកសម័យក្រោមអាណានិគមនិយមរបស់បរទេសបានរៀបចំក្រុមជំនុំព្រះត្រៃបិដកបង្កើតឡើងដកស្រង់ច្បាប់នេះពីសាស្ត្រាស្លឹករឹតមកបញ្ចូលជាសៀវភៅសំរាប់ចែកផ្សាយជូនដល់ប្រជាពុទ្ធសាសនិក រៀនសូត្រ ទាំងផ្លូវធមិ និងផ្លូវលោក បានចេះដឹងនឹងបានគោរពប្រតិបត្តិតាមច្បាប់នេះ ដោយប្រពៃដែលធ្វើអោយការយល់ដឹង ទាំងលោកុត្តរធមិ ទាំងលោកិយធមិ ដែលធ្វើអោយវប្បធមិនិងសេដ្ឋកិច្ច សង្គមជាតិមាតុភូមិនៃព្រះរាជាណាចក្រកម្ពុជាបានរីកចំរើនឡើងវិញ ប៉ុន្តែជាការអកុសលគួរភ័យខ្លាចកើតរបបព្រៃផ្សៃអានាធិបតេយ្យរបស់បនប៉ុលពត បានដុតបំផ្លាញ ច្បាប់នគរកាយនេះក៏ត្រូវអន្តរាយបាត់បង់ ដូចច្បាប់ទាំងឡាយផ្សេងៗទៀតដែរ ។ លុះដល់ថ្ងៃ ៧មករា

www.budinst.gov.kh www.elibraryofcambodia.org

ឆ្នាំ ១៩៧៩ ព.ស ២៥២៣ព្រះមហាសុមេធាធិបតី **ទេព វង្ស** សម្តេចព្រះសង្ឃរាជ គណៈមហានិកាយនៃកម្ពុជា ដែលព្រះអង្គនៅជាប្រធានសង្ឃទូទាំងប្រទេស និងជាព្រះវិន័យធរសង្ឃ ព្រះអង្គបានទៅសិក្សាប្រមូលគម្ពីរដែលសេសសល់ ខ្លះៗ ពីរបបប្រល័យពូជសាសន៍ ប៉ុលពត ព្រះអង្គបានឃើញច្បាប់សៀវភៅ នគរកាយនេះ ដែលជាឧត្តមប្រយោជន៍របស់ប្រជាពុទ្ធសាសនិក ទើបព្រះអង្គ រក្សាទុកច្បាប់នេះរហូតមកដល់ព.ស២៥៤៩ គ.ស ២០០៥ ព្រះអង្គបានរៀប រៀងផ្ទៀងប្រយោគកែលំអរពាក្យពេចន៍សំខាន់ៗខ្លះបន្ថែមអោយសមស្រប និងការគោរព ការអភិវឌ្ឍន៍ធនធានមនុស្ស និងបរិស្ថាន ហើយព្រះអង្គក៏បាន បញ្ចូលរោងពុម្ពពោធិញ្ញាណ វត្តឧណ្ណាលោមចេញជាសៀវភៅដូចច្បាប់ដើម ផ្សព្វផ្សាយអោយប្រជាពុទ្ធសាសនិក បានរៀនសូត្រតាមច្បាប់ដើមនេះនឹងបានទទួលសុខសន្តិភាព និងសប្បុរុងរឿងក្នុងព្រះនគរព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីដូចបានរៀបរាប់ខាងលើនេះ ខ្ញុំព្រះករុណាខ្ញុំ សូមខមាទោសចំពោះគតិបណ្ឌិតទាំងឡាយដែលបានអាន និងបានរៀនសូត្រក្នុងសៀវភៅនគរកាយនេះ មានលើសលស់ ឬខ្វះខាតទាំងវាក្យខ័ណ្ឌ ឃ្លាល្បះ អក្សរព្យញ្ជនៈបទបែបវប្បធម៌ រីឯ្តាំឆ្លងពាក្យពេចន៍ណាមួយ ច្រើនក្តី តិចក្តី សូមព្រះមេត្តា និងមេត្តាជួយសង្គ្រោះ និងបំពេញបន្ថែមអោយបានសមស្រប និងគតិបណ្ឌិតក្នុងច្បាប់នេះ ដោយមេត្តាករុណាធម៌ ។

ព្រះមហាសុមេធាធិបតី **ទេព វង្ស** សម្តេចព្រះសង្ឃរាជ

គណៈមហានិកាយនៃកម្ពុជា

ព.ស.២៥៤៩ គ.ស ២០០៥

www.budinst.gov.kh www.elibraryofcambodia.org

# សាស្ត្រានគរកាយ

នមោ គស្ស ។ ៣ចប់ ។ នមក្ក រត្តនត្តយស្ស ។ ឯកោ រាជា ចិត្តំនាម នគរកាយេ វន្ថំ ការេសិ។ តស្ស អគ្គមហេសី អចិន្ថារទេវី នាម បិតា មោហោ នាម មាតា លោភៈទេវី នាម។

សាធុសប្បុរសទាំងឡាយ ក្នុងនីវន្តរកាលមានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទ **ចិត្តរាជ** ជាព្រះបរមក្សត្រគ្រប់គ្រងរាជសម្បត្តិក្នុងព្រះនគរមួយឈ្មោះ **នគរកាយ** ព្រះរាជាអង្គ នោះមានអគ្គមហេសីទ្រង់ព្រះនាមនាង **អចិន្ថារទេវី** ជាទីគាប់ព្រះទ័យជាងព្រះស្នំទាំងពួង ព្រះបិតាទ្រង់ព្រះនាមព្រះបាទ **មោហរាជ** ព្រះមាតាទ្រង់ ព្រះនាមព្រះនាង **លោភទេវី** ។

នគរកាយនោះមានទ្វារ **៥** កន្លែងគឺ **ចក្ខុទ្វារ** ទ្វារភ្នែក២ **សោតទ្វារ** ទ្វារត្រចៀក២ **ឃានទ្វារ** ទ្វារច្រមុះ ២ **ជីវ្ហាទ្វារ** ទ្វារមាត់១ **បស្សាវទ្វារ** ទ្វារតូច១ **ឧច្ចារទ្វារ** ទ្វារធំ១ ។ មានប្រាង្គប្រាសាទ **៥** គឺ :

១ **ចក្ខុប្រាសាទ** ជាព្រះទីនាំងសម្រាប់ព្រះមហាក្សត្រ ទ្រង់ទតល្បែងរបាំទាំងពួង ២ **សោតប្រសាទ** ជាព្រះទីនាំងសម្រាប់ព្រះមហាក្សត្រ ទ្រង់ព្រះសណ្តាប់សូរស័ព្ទតូរ្យតន្ត្រីទាំងពួង ៣ **ឃានប្រសាទ** ជាព្រះទីនាំងសម្រាប់ព្រះមហាក្សត្រ ទ្រង់ព្រះសុគន្ធរស ៤ **ជីវ្ហាប្រសាទ** ជាព្រះទីនាំងសម្រាប់ព្រះមហាក្សត្រ ទ្រង់

www.budinst.gov.kh www.elibraryofcambodia.org

សោយព្រះសុទ្ធា ភោជនាហារដ៏មានឱជារស់ ៥ **កាយប្រសាទ** ជាព្រះទីនាំងសម្រាប់ ព្រះមហាក្សត្រ ទ្រង់គ្រឿងអលង្ការទាំងពួង មានគ្រឿងបញ្ចកកុធភ័ណ្ឌ ជាគ្រឿងសម្រាប់រាជ្យ ជាដើម ។

ព្រះបាទចិត្តរាជព្រះអង្គមានព្រះមហាតឡិក **៧** នាក់ដែលទ្រង់តាំងទុកក្នុងថានន្តរស័ក្តនាហ្មឺនមានមុខងារផ្សេងៗគ្នា សម្រាប់ជារាជបំរើតាមពេលដែលទ្រង់ត្រូវការគឺៈ ១ ហ្មឺន **ផស្សៈ** ជាអ្នកចាប់កាន់ព្រះអង្គ ២ ហ្មឺន **សញ្ញា** ជាអ្នកសំគាល់កិច្ចការទាំងពួងព្រះរាជាទ្រង់ប្រើឱ្យកត់សំគាល់ ៣ ហ្មឺន **វេទនា** ជាអ្នកនាំព្រះមហាក្សត្រ ឱ្យសោយអារម្មណ៍ផ្សេងៗ មានសុខជាដើម ៤ ហ្មឺន **ចេតនា** ជាអ្នកចាំទទួលព្រះឱង្ការ ក្នុងកាលដែលព្រះរាជាត្រូវការប្រើទៅ កាន់ទីណា ក៏ទៅបានដោយរហ័ស ៥ ហ្មឺន **ឯកគ្គតា** ជាអ្នក ស្លូតត្រង់ព្រះរាជាទ្រង់ទុកព្រះទ័យជឿយកពាក្យ ៦ ហ្មឺន **មនសិការៈ** ជាអ្នកមានចិត្តទុកដាក់នូវកិច្ចការផ្សេងៗ ដែលព្រះរាជាប្រើ ៧ ហ្មឺន **ជីវិតិន្ទ្រិយ** ជាអ្នកជួយផ្គត់ផ្គង់ព្រះជន្មព្រះរាជាឱ្យមានជីវភាព ។

ព្រះបាទចិត្តរាជព្រះអង្គមានបុរោហិត **៣** រូបទ្រង់តាំងទុកថានន្តរស័ក្តិជារាជគ្រូសម្រាប់ណែនាំព្រះអង្គ ក្នុងរាជពិធីផ្សេងៗ តាមដែលទ្រង់ត្រូវការ គឺៈ ១ រាជគ្រូ **វិតក្កៈ** ជាអ្នកណែនាំព្រះរាជា ឱ្យត្រិះរិះនូវកិច្ច ការផ្សេងៗ ២ រាជគ្រូ **វិចារៈ** ជាអ្នកណែនាំព្រះរាជាឱ្យពិចារណានូវកិច្ចការផ្សេងៗ ៣ រាជគ្រូ

www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

ធិរមោរក្ខា ជាអ្នកណែនាំព្រះរាជា ឱ្យមានព្រះទ័យ តាំងសប់ក្នុងកិច្ចការផ្សេងៗ។

ព្រះបាទចិត្តរាជព្រះអង្គ មាន ព្រះឥសី ៣ រូបប្រកបដោយអភិញ្ញា និង សមាបត្តិ ព្រះអង្គតាំងទុកក្នុងឋានន្តរស័ក្ត ជាអ្នកពន្យល់ព្រះអង្គ គឺ :១ ព្រះ បីតិ ជាអ្នកពន្យល់ព្រះអង្គ ឱ្យមានអំណរដ៏ត្រជាក់ជ្រួតជ្រាបផ្សព្វផ្សាយក្នុងអារម្មណ៍ ផ្សេងៗ ២ ព្រះ ឆន្ទា ជាអ្នកពន្យល់ព្រះរាជា ឱ្យមានព្រះទ័យស្រលាញ់ នូវកិច្ចការទាំងពួង ៣ ព្រះ វីរិយា ជាអ្នកពន្យល់ព្រះរាជាឱ្យមានព្រះទ័យ ព្យាយាមក្នុងកិច្ចការផ្សេងៗ។

មិនតែប៉ុណ្ណោះព្រះបាទចិត្តរាជ ព្រះអង្គ មានព្រះភិក្ខុ៣ អង្គ ទ្រង់តាំងទុក ក្នុងសមណៈស័ក្ត ជា ព្រះជីតុន សម្រាប់ជួយរំលឹកដាស់តឿនព្រះអង្គ គឺ : ១ ព្រះ អនិច្ចំ ជា អ្នករំលឹក ព្រះរាជា ឱ្យនឹកឃើញសេចក្តីមិនទៀងរបស់សង្ខារ ២ ព្រះ ទុក្ខំ ជាអ្នករំលឹក ព្រះរាជា ឱ្យនឹកឃើញសេចក្តីទុក្ខរបស់សង្ខារ ៣ ព្រះ អនត្តា ជាអ្នករំលឹក ព្រះរាជា ឱ្យនឹកឃើញ សេចក្តី មិនមានខ្លឹមសាររបស់សង្ខារ ។

ព្រះជីតុនទាំង ៣ រូប តែងរំលឹកធម៌អាថ៌ ចំពោះព្រះមហាក្សត្រ ឱ្យទ្រង់ ពិចារណា ឃើញតាមពិតក្នុងព្រះត្រៃលក្ខណញ្ញាណ មិនឱ្យធ្វេសប្រហែសក្នុង កុសលធម៌ទាំងពួង ។

ព្រះបាទចិត្តរាជ ព្រះអង្គមានព្រះញាតិវង្ស ១៤ ព្រះអង្គ ថាព្រះញាតិវង្ស

ខាងព្រះមាតា បិតា ជាបាបជនមានយោបល់ មិនប្រពៃ ព្រះអង្គតាំងទុកថានន្តរស័ក្ក ជាឃុនគ្រប់រូបគឺ : ១ ឃុន **មោះហា** ជាអ្នកនាំរាជាឱ្យវង្វេង ២ ឃុន **អហិរិកំ** ជាអ្នកនាំព្រះ រាជាមិនឱ្យខ្មាសបាប ៣ ឃុន **អនោត្តប្បំ** ជាអ្នកនាំព្រះរាជាមិនឱ្យខ្លាចបាប ៤ ឃុន **ឧទ្ធច្ចំ** ជាអ្នកនាំព្រះ រាជាឱ្យរាយមាយ ៥ ឃុន **លោភោ** ជាអ្នកនាំព្រះរាជា ឱ្យលោភ ៦ ឃុន **ទិដ្ឋិ** ជាអ្នកនាំព្រះរាជាឱ្យយល់ខុស ៧ ឃុន **មានោ** ជាអ្នកនាំព្រះរាជាឱ្យប្រកាន់ព្រះអង្គ ៨ ឃុន **ទោសោ** ជាអ្នកនាំព្រះរាជា ឱ្យប្រទុស្តគេ ៩ ឃុន **ឥស្សា** ជាអ្នកនាំព្រះរាជាឱ្យច្រណែនគេ ១០ ឃុន **មច្ឆរិយ** ជាអ្នកនាំព្រះ រាជាឱ្យកំណាញ់ ១១ ឃុន **កុក្កុច្ចំ** ជាអ្នកនាំព្រះរាជា ឱ្យអន្ទះអន្ទែង ១២ ឃុន **ថីនំ** ជាអ្នកនាំព្រះរាជាឱ្យរួញរា ១៣ ឃុន **មិទ្ធំ** ជាអ្នកនាំ ព្រះរាជាឱ្យងុយងោក ១៤ ឃុន **វិចិកិច្ឆា** ជាអ្នកនាំព្រះរាជាឱ្យសង្ស័យ ។

ព្រះញាត្តិវង្សទាំង ១៤ អង្គនេះ ជាទីទុកព្រះទ័យព្រះបាទចិត្តរាជ យ៉ាងជិតស្និត ព្រះអង្គតែងប្រោណប្រាណ ឱ្យចូលជិតគាល់បំរើជានិច្ចកាលពុំដែលខានពេលណាមួយឡើយ។ ព្រះរាជាចិត្តរាជ ព្រះអង្គមាន អគ្គសេនា **១៩** នាក់ជាវរជនមានយោបល់ល្អៗ ព្រះអង្គតាំងទុកក្នុងថានន្តរសក្តិជាឧកញ៉ាគ្រប់រូបគឺ: ១ ឧកញ៉ា **សទ្ធា** ជាអ្នកនាំព្រះរាជា ឱ្យជឿកម្មផល ២ ឧកញ៉ា **សតិ**

www.budinst.gov.kh www.elibraryofcambodia.org

ជាអ្នកនាំព្រះរាជា ឱ្យមានស្មារតី ៣ ឧកញ៉ា **ហិរិ** ជាអ្នកនាំព្រះរាជ ឱ្យខ្មាស់បាប ៤ ឧកញ៉ា **ឱត្តប្ប** ជាអ្នកនាំព្រះរាជាឱ្យខ្លាចបាប ៥ ឧកញ៉ា **អលោភៈ** ជាអ្នកនាំព្រះរាជា មិនឱ្យ លោភ ៦ ឧកញ៉ា **អទោសៈ** ជាអ្នកនាំព្រះរាជាមិនឱ្យ ប្រទូសគេ ៧ ឧកញ៉ា **តត្រមជ្ឈត្តតា** ជាអ្នកនាំព្រះរាជាមានព្រះទ័យជាកណ្ដាល ៨ ឧកញ៉ា **កាយបស្សទ្ធិ** ជាអ្នកនាំព្រះរាជា ឱ្យមានព្រះនាមកាយរម្ងាប់ ៩ ឧកញ៉ា **ចិត្តបស្សទ្ធិ** ជាអ្នកនាំព្រះរាជា ឱ្យមានព្រះទ័យរម្ងាប់ ១០ ឧកញ៉ា **កាយលហុតា** ជាអ្នកនាំព្រះរាជាឱ្យមានព្រះកាយស្រាល១១ ឧកញ៉ា **ចិត្តលហុតា** ជាអ្នកនាំព្រះរាជា ឱ្យមានព្រះទ័យស្រាល ១២ ឧកញ៉ា **កាយមុទិតា** ជាអ្នកនាំព្រះរាជា ឱ្យមានព្រះនាមកាយទន់ភ្លន់ ១៣ ឧកញ៉ា **ចិត្តមុទិតា** ជាអ្នកនាំព្រះរាជា ឱ្យមានព្រះទ័យទន់ភ្លន់ ១៤ ឧកញ៉ា **កាយកម្មញ្ញតា** ជាអ្នកនាំព្រះរាជា ឱ្យមានព្រះនាមកាយគួរដល់ការងារ ១៥ ឧកញ៉ា **ចិត្តកម្មញ្ញតា** ជាអ្នកនាំព្រះរាជា ឱ្យមានព្រះទ័យគួរដល់ការងារ ១៦ ឧកញ៉ា **កាយបាគុញ្ញតា** ជាអ្នកនាំព្រះរាជា ឱ្យមានព្រះនាមកាយជំនាញ ១៧ ឧកញ៉ា **ចិត្តបាគុញ្ញតា** ជាអ្នកនាំព្រះរាជា ឱ្យមានព្រះទ័យជំនាញ ១៨ ឧកញ៉ា **កាយុជុកតា** ជាអ្នកនាំព្រះរាជាឱ្យមានព្រះនាមកាយត្រង់ ១៩ ឧកញ៉ា **ចិត្តុជុកតា** ជាអ្នកនាំព្រះរាជា ឱ្យមានព្រះទ័យត្រង់ ។

www.budinst.gov.kh www.elibraryofcambodia.org

អគ្គសេនាទាំង ១៩ នាក់នេះជាទីទុកព្រះទ័យ ព្រះរាជាចិត្តរាជព្រះអង្គទ្រង់តាំងទុក ជាឧត្តមក្រុមប្រឹក្សាសម្រាប់ជុំនុំ ការរាជការ ផែនទឹក ផែនដីនៃនគរកាយ តាងព្រះនេត្រព្រះកាណ៌ព្រះអង្គ ។

ព្រះរាជាចិត្តរាជ ព្រះអង្គគ្រប់គ្រងរាជសម្បត្តិ ជាសម្បូរណាថ្វាសិទ្ធិរាជមានព្រះរាជសិទ្ធិអំណាច ដ៏សម្បូរមហិមារ ជាសុខសប្បាយក្នុងកាយប្រទេសល្បីឮសុះសាយទូរទៅដល់ប្រទេសនានា ។

ឯកោ រាជា មច្ចុ នាម មហិទ្ធិកោ អហោសិ ។

សាធុសប្បុរសផងទាំងឡាយ ! ក្នុងទីមិនឆ្ងាយពីនគរកាយនោះ មានព្រះរាជាមួយព្រះអង្គទៀតព្រះនាម ព្រះបាទ **មច្ចុរាជ** ជាព្រះរាជាដ៏មានមហិទ្ធិរិទ្ធីមានសណ្ដានអាក្រក់ដែលត្រាចទៅគ្របសង្កត់សព្វសត្វក្នុងត្រៃភព តាំងពីមនុស្សលោកដល់ព្រហ្មលោក ឱ្យស្ថិតនូវក្នុងកណ្ដាប់ព្រះហស្តព្រះអង្គ ស្ដេចមានចតុរង្គសេនា ៤កងពល ធំ សុទ្ធតែជាមេទ័ពដ៏មានប្រត្តិពលក្នុងកលោបាយ និង យុទ្ធពិធីគ្រប់ជុំពូកមានឥទ្ធិរិទ្ធចេស្ដាមហិមា អាចផ្ចាញ់បច្ចាមិត្តគ្រប់ទិសានុទិសឱ្យបរាជ័យ ឥតបើមានអ្នកណាមួយក្នុង ត្រៃលោកតស៊ូបានឡើយ ។

ចតុរង្គសេនាទាំង ៤ កងពលធំនោះមានមេទ័ព ៤ នាក់គឺ: ១ នាយ **ជាតិ** ជាមេទ័ព មានសមត្ថភាព ខាងស្ថាបនា វត្ថុធាតុផ្សេងៗ ដែលមិនទាន់កើតឱ្យកើត

ឡើង ២ នាយ ឫទ្ធិ ជាមេទព័មានសមត្ថភាពខាងធ្វើវត្ថុធាតុផ្សេងៗ ដែលខ្មាំងបង្កើតឡើងហើយឱ្យទ្រុតទ្រោមទៅ ៣ នាយ ព្យាធិ ជាមេទព័មានសមត្ថភាពខាងធ្វើខ្មាំង ដែលមានកំលាំងខ្លាំងរឹងប៉ឹងឱ្យទុព្វលភាព ៤ នាយ មរណៈ ជាមេទព័មានសមត្ថភាពខាង សម្លាប់ខ្មាំងដែលពូកែឱ្យស្លាប់បានគ្មានគេចរួចម្នាក់ ។ មេទព័ម្នាក់ៗមានបរិវារច្រើនតែងចេញចូលគាល់ បំរើ ការពារអង្គព្រះបាទ មច្ចុរាជ ជានិច្ចកាល ព្រះបាទមច្ចុរាជ តែងទ្រង់ប្រើទៅយាយីសម្លាប់ពួកខ្មាំង ទាំងពួងក្នុងត្រៃលោក ។

កិត្តិស័ព្ទព្រះបាទចិត្តរាជ បានល្បីរន្ទឺព្ធសាយទៅព្រះបាទមច្ចុរាជថា មានព្រះនគរមួយឈ្មោះ នគរកាយ ជាស្រុកនីរទុក្ខ សុខសប្បាយក្រៃពេក ព្រះរាជាជាប្រមុខនគរនោះ ព្រះនាមព្រះបាទ ចិត្តរាជ ជាបរមក្សត្រ គ្រងសិរីសម្បត្តិសម្បូរដោយព្រះរាជអំណាចមហិមា ។

កាលដំណឹងនោះ ព្ធសាយទៅដល់ព្រះស្រោត ព្រះបាទមច្ចុរាជ ក៏ទ្រង់វិតក្កយ៉ាងក្រៃលែង ខ្លាចក្រែងព្រះបាទ ចិត្តរាជកន្លងវិស័យនៃព្រះអង្គ ទ្រង់មានព្រះរាជបំណងនឹង ប្រើមេទ័ពទាំងបួនកង ឱ្យទៅវាយដណ្តើមយក នគរកាយនោះ ឱ្យនៅក្រោមអំណាចព្រះអង្គមួយរំពេច តែស្តេចទ្រង់ព្រះតម្រេះឃើញថា :

"ព្រះបាទចិត្តរាជ ជាព្រះមហាក្សត្រ ដ៏មានអានុភាពមហិមា មានសេនាទាហាន

www.budinst.gov.kh www.elibraryofcambodia.org

សព្វមុខមន្ត្រី កុះករបរិបូណ៌ ក្រៃពេក ។ បើអាត្មាលើកទ័ពទៅកាច់យកភ្លាម១ ឃើញថាពុំងាយបានឡើយ ។ ណ្ហើយកុំធ្វើដូច្នោះ ចាំអាត្មាអញប្រើចារទាហាន ទៅលលួងយកដោយកលោបាយវិញ គឺអាត្មាអញត្រូវបញ្ជូន មេទ័ពដ៏មានសមត្ថភាពឱ្យទៅក្លែងធ្វើជាខ្ញុំបំរើផ្ទាល់ព្រះបាទចិត្តរាជជាមុនសិន កាលបើចារទាហានអាត្មាអញ ទៅប្រតិបត្តិបត្តិការបានសម្រេចហើយ សឹមអាត្មាអញឱ្យលើកកងទ័ពទៅវាយយកតាមក្រោយ បើធ្វើដូច្នោះ ប្រហែលជាងាយ" ។

កាលព្រះបាទមច្ចុរាជទ្រង់តម្រិះឃើញឧបាយដូច្នេះ ហើយក៏ទ្រង់បញ្ជាឱ្យមេទ័ពទីមួយ ឈ្មោះនាយជាតិ លុះនាយជាតិចូលមកគាល់ស្តេចក៏ទ្រង់ត្រាស់ថា នែនាយជាតិចូរបារទទួលយកអាសារយើង ក្នុងគ្រាឥលូវនេះចូរឯងទៅកាន់នគរកាយជាប្រញាប់ កាលទៅដល់ចូរបារឯង ទៅអែបអបធ្វើខ្លួន ឱ្យជាទីជិតស្និទ្ធសាលជាមួយនឹងសេវកាមាត្យ ព្រមទាំងមាតា បិតា វង្សាគណាញាតិ នៃព្រះបាទចិត្តរាជ បើបារឯងបាន ជាទីស្និទ្ធ ស្នាលនឹងគេហើយ ចូរបារឯងចូលថ្វាយខ្លួនជាខ្ញុំគាល់បម្រើគេជានិច្ច និងខំធ្វើរាជការគេឱ្យល្អ ឱ្យគេរាប់អាន ទុកចិត្តស្រលាញ់បា ដើម្បីនឹងបានជា សយ្យសឹក (សត្រូវដែលដេកកើតក្នុងផ្ទៃក្នុង) ក្នុងស្រុកគេ កាលធ្វើការបាន សម្រេចហើយ ចូរបាឯងធ្វើដំណើងមកយើង " ។

លុះត្រាស់ដូច្នោះ ក៏ទ្រង់បញ្ជូននាយ ជាតិអោយទៅកាន់នគរកាយ ឯ

www.budinst.gov.kh www.elibraryofcambodia.org

នាយជាតិកាលបានទទួលព្រះរាជឱង្ការហើយ ក៏នាំបរិវារធ្វើដំណើរឆ្ពោះទៅកាន់នគរ កាយ នោះទៅតាមព្រះរាជបញ្ជា ។

លុះនាយជាតិបានទៅដល់កាលណា ក៏ចូលទៅធ្វើជាមិត្តសិទ្ធស្នាលជាមួយនឹងនាយហ្មឺនសព្វមុខមន្ត្រីដោយសេចក្តីឆ្លៀវឆ្លាសរបស់ខ្លួន ហើយក៏ចូលទៅផ្គាប់ផ្គុនព្រះមាតា.បិតាអគ្គមហេសីនិងញាតិវង្ស នៃព្រះបាទចិត្តរាជ.វរជនទាំងនោះគេស្រលាញ់ពេញចិត្តអាណិតអាសូរខ្លួនហើយ ក៏ឱ្យគេនាំខ្លួនទៅថ្វាយព្រះមហាក្សត្រ ។ វរជនទាំងនោះ ក៏នាំនាយជាតិទៅ ថ្វាយខ្លួនចំពោះព្រះបាទចិត្តរាជ កាលបើមានករណីប្លែកដូច្នោះ ព្រះបាទចិត្តរាជ ទ្រង់មានព្រះរាជ ឱង្ការ ឱ្យអញ្ជើញរាជគ្រូ **ទិតភ្ញា ទិចារវា អធិមោភ្ញា** ជាបុរោហិតទាំង ៣ មកត្រាស់ប្រឹក្សាថា:លោកទាំងពួងយល់ឃើញដូចម្តេចរឿងនេះ គួរយើងទទួលយកជនបរទេសនេះទុកក្នុងស្រុកយើងឬពុំគួរ ឯបុរោហិតទាំង ៣ រូបនោះហេតុតែជា អ្នកមិនឈ្លាស ក្នុងកលនយោបាយផ្សេងៗថែមទាំងជាអ្នកលេះលោះផង ឃើញអ្នកណា គេផ្គប់ផ្គុនក៏ទន់ចិត្តទៅតាម គេមិនគិតរិះរកពិចារណារកហេតុផលឱ្យល្អិតល្អជាមុនឡើយ ។កាលព្រះរាជាត្រាស់សួរដូច្នោះ បុរោហិតក៏ក្រាបបង្គំទូលភ្លាមថា បពិត្រមហារាជដ៏ទ្រង់នូវព្រះសម្ភារ បើមានជនបរទេសគេស្ម័គ្រចូលមកថ្វាយខ្លួនជាខ្ញុំបំរើ ប្រើប្រាស់ផ្ទាល់ខ្លួនក្រោមលម្អងធូលី ព្រះបាទព្រះអង្គដោយទ្រង់ឥត

www.budinst.gov.kh www.elibraryofcambodia.org

មានទាក់ទិនអ្វីដូច្នោះ ចូរទ្រង់ទទួលយកចុះ ព្រះបាទចិត្តរាជបរមក្សត្រ កាលបានទ្រង់ព្រះសណ្តាប់ដូច្នោះ ក៏រាជានុមត្តិឱ្យជប់លៀងនាយជាតិហើយឱ្យគេនូវជាខ្ញុំរាជការតទៅ នាយជាតិបានឧស្សាហ៍ធ្វើការ ថ្វាយព្រះបាទចិត្តរាជ១ទ្រង់រាជទានគ្រឹះស្ថានឱ្យនាយជាតិព្រមទាំងបរិវារនូវជាសុខសប្បាយ ។

ចាប់ដើមពីនោះមកនាយជាតិព្រួតដៃជាមួយមេជាងឈ្មោះ គណ្ឋា ដែលជាជាងធំនូវក្នុងនគរកាយនោះ ស្រាប់នាំគ្នាឧស្សាហ៍កសាងនគរកាយត្រង់ណាដែលមិនទាន់ស្រេច ក៏សម្រេចដោយរហ័សត្រង់ណាដែលស្រេចហើយឱ្យចំរើនឡើងសព្វទិវារាត្រី ញ៉ាំងព្រះបាទចិត្តរាជឱ្យទុកព្រះទ័យពន់ពេក ។កាលបានឱកាសល្អនាយជាតិជាមេទព្វទី ១ បញ្ជូនចុតហ្មាយទៅថ្វាយព្រះបាទមច្ចុរាជថា "សូមព្រះរាជតេជៈដម្កល់លើត្បូងសូមព្រះរាជទានក្រាបបង្គំទូល ព្រះករុណាជាម្ចាស់ជីវិតសូមជ្រាបក្រោមល្អងធូលី សូមទ្រង់ព្រះមេត្តាប្រោសករណីកិច្ចដែលព្រះអង្គប្រើទូលព្រះបង្គំឱ្យទៅជាចារបុសធ្វើការឯនគរកាយនោះ ឥឡូវនេះទូលព្រះបង្គំ ធ្វើតាមព្រះរាជបញ្ជាបានសម្រេចគ្រប់ប្រការហើយ សូមទ្រង់បញ្ជូនមេទព្វទី ២ ទៅទៀតដើម្បីប្រតិបត្តិការថ្វាយល្អងធូលី ព្រះបាទឱ្យបានសម្រេចតទៅ" ។ហត្ថលេខានាយជាតិ ។

ព្រះបាទមច្ចុរាជាធិរាជកាលអានចុតហ្មាយនោះហើយ ក៏ទ្រង់ប្រើ នាយឧវាទ

www.budinst.gov.kh www.elibraryofcambodia.org

ជាមេទព័ទី២ ឱ្យលើកទ័ពចេញទៅទៀតដើម្បីឱ្យមេទ័ពនោះ ធ្វើនគរកាយឱ្យទ្រុឌទ្រោមហើយនឹងបញ្ជូនមេទព័ធំ១ដ៏ទៃទៀតទៅតាមក្រោយនាយជរាទទូលព្រះរាជឱង្កាហើយក៏នាំបរិវារទៅកាន់នគរកាយដោយសួស្ដីលុះដល់ហើយតម្រង់រកនាយជាតិជាពូករបស់ខ្លួន ដែលមកនៅមុននាយជាតិក៏ទទូលនាយជរាទុកនៅជាមួយគ្នាក្នុងនគរកាយនោះ ដោយសិរីឥតបីឱ្យគេនាំទៅថ្វាយ ព្រះបាទចិត្តរាជដូចមុនឡើយ។ តាំងពីនោះមកនាយជាតិនិង នាយជរាក៏នាំ បរិវាររៀង១ខ្លួនត្រាចរុករានទន្ទ្រាននគរកាយ គឺរូបកាយយើងគេគ្រប់គ្នា ឱ្យចាស់គ្រាំគ្រា មួយ ថ្ងៃបន្តិច១តាមលំដាប់។

ឯព្រះ អនិច្ចំ ជាព្រះជីតុនកាលបានជ្រាបក៏ចូលទៅថ្វាយព្រះពររំឭក ព្រះបាទចិត្តរាជថា:"បពិត្រព្រះមហារាជដ៏ទ្រង់នូវព្រះសម្ភារ!ឥឡូវនេះព្រះនគរកាយគ្រប់ព្រះអង្គ ព្រះអង្គគ្រាំគ្រាហើយមិនមាំមួនដូចមុនទេដោយមច្ចុរាជសត្រូវពីខាងក្រៅចូលមកបំផ្លាញ សូមព្រះអង្គគិតគួរឱ្យមែនទែនកុំបីធ្វេសប្រហែស"។

កាលព្រះជីតុនរំលឹកដូច្នោះព្រះបាទចិត្តរាជនិងបានព្រឺខ្លាចសូម្បីតែប៉ុនចុងសក់ក៏ ទេដោយវង្វេងតាមព្រះនាងអវិជ្ជាទេវីជាអគ្គហេសីពុំមានឱកាសចេញទៅទតព្រះនគរកាយបានឡើយ។ព្រះអនិច្ចំ ជាព្រះជីតុនកាលបានឃើញ ព្រះចិត្តរាជនៅព្រងើយដូច្នោះ ទើបចូលទៅថ្វាយព្រះពរតឿនម្តងទៀតថា :"បពិត្រមហារាជ

ដំទ្រង់នូវព្រះករុញ្ញភាព ! ហេតុម្តេចព្រះអង្គគង់ស្ងៀមដូច្នោះ ? មិនសមគួរទេព្រះអង្គ ! ឥឡូវព្រះនគរកាយរបស់ព្រះអង្គ គ្រាំគ្រាហើយ សូមស្តេចយាងទៅទតខ្លះផង " ។

លុះព្រះជីតុនដាស់តឿនដល់ទៅពីរដងព្រះបាទចិត្តរាជទ្រាំគង់ស្ងៀមពុំបាន ក៏ទ្រង់ស្តេចទៅទតបន្តិចក៏ឃើញដូចពាក្យព្រះជីតុនរំលឹកមែន តែគង់នៅស្ងៀមដដែល ពុំបានគិតដល់ព្រះនគរឡើយ ។ ទោសទាំងនេះមកតែពីទ្រង់វង្វេងដោយព្រះនាងអវិជ្ជាទេវី ។

កាលនាយជាតិ និងនាយជរាជាមេទព្វទាំង ២ នាក់ឃើញអាការដូច្នោះ ក៏បញ្ជូនសារទៅថ្វាយព្រះបាទមច្ចុរាជថា "សូមព្រះរាជតេជៈដម្កល់លើត្បូងសូមព្រះរាជទានក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតសូមទ្រង់មេត្តាប្រោស ។ឥឡូវនេះព្រះបាទចិត្តរាជកំពុងប្រមាទ សូមបញ្ជូនមេទព្វទី ៣ ព្រមទាំងយោធាបរិវាទៅទៀត ដើម្បីប្រតិបត្តិការ ឱ្យឆាប់បានសម្រេចទាន់ព្រះរាជហឫទ័យតទៅ" ។ ហត្ថលេខា នាយជាតិ ជរា ។លុះព្រះបាទមច្ចុរាជបានទ្រង់ជ្រាបព្រឹត្តិការណ៍នោះ ទើបទ្រង់ព្រះរាជបញ្ជាប្រើនាយ **ព្យាធិ** ជាមេទព្វកំណាចទី៣ ព្រមទាំងបរិវា ៩៦ នាក់គឺ **ឆន្នវុតិរោគ** ឱ្យមកកាន់ នគរកាយ ។ នាយព្យាធិព្រមទាំងបរិវារ ក៏នាំទៅតាមព្រះរាជបញ្ជា កាលទៅដល់ហើយ នាយព្យាធិព្រមទាំងបរិវារ ៩៦

www.budinst.gov.kh www.elibraryofcambodia.org

នាក់បានញាំញីកំទិចនូវទ្វារនគរ និងបន្ទាយតូចធំ ព្រមទាំងគ្រឿងប្រដាប់ផ្សេងៗ អោយរលាយបាក់បែកគ្រប់អន្លើអ្នកនគរកើតចលាចលរកចេញចូលពុំបាន ។ ធ្វើទាំងនេះដោយប្រាថ្នាចាប់យក ព្រះបាទចិត្តរាជ មួយមុខប៉ុណ្ណោះ ឯព្រះបាទ ទុក្ខជាព្រះជីតុនកាលបានឃើញក៏ចូលទៅថ្វាយព្រះពរ ព្រះបាទចិត្តរាជថា:

"បពិត្រមហារាជ ដ៏ទ្រង់នូវព្រះតេជានុភាព! ព្រះអង្គពុំទាន់ជ្រាបទេឬ? ឥឡូវនេះព្រះនគរកាយនៃ ព្រះអង្គវិកលវិការហើយ ដោយនាយជាតិជាមេទព្វទី១ ដែលចូលមកនូវមុនបង្អស់ គេគប់គិតគំនិតជាមួយ នាយជរា ជាមេទព្វទី២ និងនាយព្យាធិជាមេទព្វទី៣ ព្រមទាំង **ឆន្នវុតិរោគ** ៩៦ នាក់ជាបរិវារ នាំគ្នាធ្វើឱ្យវឹកវរបើព្រះអង្គធ្វើព្រងើយកន្តើយ ព្រះនគរកាយមុខជាអន្តរាយមិនខានសូមទ្រង់ជ្រាប"។

ព្រះបាទចិត្តរាជបរមក្សត្រ កាលបានទ្រង់ព្រះសណ្តាប់ដូច្នោះ ក៏រសាប់រសល់ក្នុងព្រះហឫទ័យទ្រង់ស្តេចចេញទៅទតសព្វសព៌ាង្គព្រះនគរកាយ លុះឃើញច្បាស់ក៏ សោយទុក្ខវេទនា ទ្រង់ព្រះកន្សែងខ្សឹកខ្សួលជាខ្លាំង រកបុគ្គលណាមួយជួយយកអាសារកំចាត់ ព្យាធិសេនាជាខ្មាំងសត្រូវពុំបាន ដោយមហាជនទាំងពួងសឹងតែខ្លាចអំណាចព្យាធិសេនាទាំងអស់គ្នា ។

លុះនាយជាតិជរា ព្យាធិ ជាមេទព្វទាំង ៣ នាក់បានឃើញអាការដូច្នោះ ក៏

www.budinst.gov.kh www.elibraryofcambodia.org

បញ្ជូនសាទៅថ្វាយព្រះបាទមច្ចុរាជថា: "សូមព្រះតេជ:ដម្កល់លើត្បូង សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិត សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ សូមទ្រង់មេត្តាប្រោស ឥឡូវនេះព្រះបាទជិត្តរាជ ខ្សោយកំលាំងណាស់ហើយ សូមទ្រង់បញ្ជូនមេទព័ទី៤ ទៅទៀតជាប្រញាប់ ដើម្បីព្រួតគ្នាចាប់តួព្រះបាទចិត្តរាជយកមកថ្វាយយ៉ាងរួសរាន់ ។ ហត្ថលេខា នាយ ជាតិ ជរា ព្យាធិ ។

កាលព្រះបាទមច្ចុរាជ បានទ្រង់ជ្រាបព្រឹត្តិហេតុនោះ ក៏ទ្រង់បញ្ជូនមេទព័ទី ៤ ធំបំផុតឈ្មោះនាយ **មរណៈ** ដ៏មានអានុភាពមហិមាជាងមេទព័មុនៗ អាចប្រាមប្រាប់បច្ចាមិត្តគ្រប់ទិសតំបន់ ឱ្យវិនាសអន្តរាយកណ្តាលសមរភូមិ ។ សត្វនិករ ក្នុងត្រៃលោកសឹងកោតខ្លាចអំណាចមេទព័នេះណាស់ គ្រាន់តែឮឈ្មោះថាមរណៈសេនាមកជិតដល់សឹងតែ នាំគ្នារត់ជ្រកយកអាយុ រៀងខ្លួនៗតែទោះបីអ្នកណារត់ទៅពួនក្នុងទីណាៗក្តី ក៏ពុំរួចពីកណ្តាប់ដៃនាយមរណៈនោះបានឡើយ ។

ឯមេទព័ទី ៤ ឈ្មោះនាយមរណៈ កាលបានទទួលព្រះរាជបញ្ជាហើយក៏នាំបរិវារទៅកាន់នគរកាយ លុះ ចូលទៅដល់ផ្សំគ្នានឹងមេទព័ទាំង ៣ នាក់ដែលមកមុននោះហើយក៏រុករានទន្ទ្រាន បុកបែនញាំញីទ្វារទាំង៩នៃនគរកាយ ឱ្យងងិតជុំវិញហើយចូលទៅដេញចាប់តួអង្គព្រះបាទចិត្តរាជបានព្រមទាំងសព្វមុខមន្ត្រីនិងអណាប្រជាជនទាំងពួងគ្មានសល់ម្នាក់ នាំចេញចាកនគរកាយ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯនគរកាយនេះ កាលបើគ្មានបុគ្គលណាមួយនៅហើយក៏ទ្រុឌទ្រោមទៅ។ នគរកាយគឺរាងកាយយើងគេទាំងពួង ព្រះបាទចិត្តរាជ គឺចិត្តយើងគេទាំងពួង និមិត្តតែចិត្ត ពុំឋិតនៅក្នុងរាងកាយហើយ រាងកាយក៏ពុំ អាចទប់ទល់នៅបានតែង ដល់នូវសភាពជារាងកាយស្អុយរលួយ ជាធម្មតា ដោយប្រការដូច្នេះ។

សាធុសប្បុរសទាំងឡាយកាលមេទព្វទាំ ៤ នាក់ព្រមទាំងបរិវារចាប់ព្រះបាទចិត្តរាជបានហើយ ក៏ នាំទៅកាន់សំណាក់ ព្រះបាទមច្ចុរាជ។ ឯព្រះបាទមច្ចុរាជ កាលឱ្យចាប់ ព្រះបាទចិត្តរាជ បានមកហើយនឹងយកទុកជាខ្ញុំបំរើក៏ទេ ត្រឡប់ជាបណ្តេញទៅវិញថា:"ចូរអ្នកឯងទៅតាមយថាកម្ម ខ្លួនចុះ"!។

លំដាប់ពីនោះមក ព្រះបាទចិត្តរាជ ក៏នាំបរិវារទៅរកទីលំនៅកសាងនគរកាយសាជាថ្មីដូចមុន។

ឯព្រះបាទមច្ចុរាជជា ស្តេចកំបាប កាលបានជ្រាបព្រះបាទចិត្តរាជ ក៏សាងនគរកាយជាថ្មីក៏ទ្រង់ប្រើ មេទព្វទាំង ៤ ឱ្យទៅតាមបៀតបៀន ចាប់តួអង្គព្រះបាទចិត្តរាជ ឱ្យព្រាត់ចាកនគរកាយថ្មីនោះទៀត និមិត្តតែព្រះបាទចិត្តរាជ កសាងនគរកាយវេលាណា ក៏ធ្វើផឱ្យអន្តរាយវេលានោះរាល់គ្រាពុំដែលខានម្តងណាឡើយ ព្រះបាទចិត្តរាជក៏ទ្រង់សោយទុក្ខវេទនាគ្មានស្រាកស្រាន គ្រាមួយជាវេលាមានជោគវេសនាល្អ ព្រះបាទចិត្តរាជ ក៏ទ្រង់ព្រះតម្រិះថា: "អាត្មា

www.budinst.gov.kh www.elibraryofcambodia.org

អញធ្វើម្ដេចនិងបានរួចពីកណ្ដាប់ដៃមច្ចុរាជនេះបានអេះ! ឱ ហ្ន៎ អាត្មាអញនឹងឱ្យទៅអារាធនាព្រះភិក្ខុជាព្រះជីតុន និង ឥសីចូលមកប្រឹក្សាគ្នាក្រែងលោកឃើញឧបាយយ៉ាងណាខ្លះ?"។លុះទ្រង់ព្រះតម្រិះហើយ ក៏ទ្រង់ព្រះបញ្ជាប្រើ មហាតឡិក ២ នាក់គឺហ្មឺន **ចេតនា** ជាមហាតលិកស្ដាំនិងហ្មឺន **មនសិការោ** ជាមហាតឡិកឆ្វេងថា: "នែបាទាំងឡាយ!

ចូរបាយកអាសារយើងទៅអារាធនាព្រះភិក្ខុជាព្រះ ជីតុនទាំង ៣ រូបគឺព្រះ **អនិច្ចំ ទុក្ខំ អនត្តា** និងព្រះឥសីទាំង ៣ រូបគឺព្រះ **បីតិ ឆន្ទោ វិរិយោ** នូវបុរោហិតទាំង ៣ រូបគឺ ព្រះរាជគ្រូ **វិតក្កោ វិចារោ អធិមោក្ខោ** ហើយនឹងអគ្គសេនាទាំង ១៩នាក់មានឧកញ្ញា **សទ្ធា** ជាដើមឱ្យមកកាន់សំណាក់យើងក្នុងខណៈនេះ"។

មហាតឡិកទាំង ២ នាក់ក៏ម្ទីរម្នាទៅរក វរសមណៈនិងវរជនទាំងនោះតាមព្រះរាជបញ្ជា។ វរសមណៈនិងវរជនទាំងនោះ ក៏នាំគ្នាទៅកាន់ព្រះរាជសំណាក់តាមសេចក្ដីអារាធនា អញ្ជើញ លុះទៅដល់ព្រះបាទចិត្តរាជ ក៏ត្រាស់ប្រឹក្សាការផែនដីថា "បពិត្រលោកអ្នកនីរទុក្ខទាំងឡាយ! ខ្ញុំសូមប្រឹក្សានឹងលោក សូមលោកជួយរក ឧបាយ ដើម្បីឱ្យខ្ញុំរួចចាកកណ្ដាប់ដៃនៃមច្ចុរាជ "។

ព្រះជីតុន ព្រមទាំងវរជនទាំងពួង ដែលបានជួបជុំក្នុងមហាសន្និបាទនោះ

ថ្វាយព្រះពរឡើងព្រមគ្នាថា "បពិត្រព្រះសម្មតិទេវរាជ! ការប្រឹក្សាគ្រានេះជាការធំដុំណាស់ ការនេះដែលនិងសម្រេចដាច់ខាតទៅបានលុះ តែមាន សម្ដេចព្រះមហាសង្ឃរាជ ទាំង ២ ព្រះអង្គគឺព្រះ **សមាធិន្រ្ទិយ** និងព្រះ **បញ្ញិន្រ្ទិយ** មកជាទី ប្រឹក្សាផង សូមព្រះអង្គឱ្យទៅ អារាធនាសម្ដេចមក"។

ព្រះបាទចិត្តរាជបានទ្រង់ព្រះសណ្ដាប់ទីប្រជុំ ក៏ទ្រង់ត្រាស់ប្រើហ៊ឺន **ឯកគ្គតា** ជាមហាតឡិកដ៏មានចិត្ត ស្លូតត្រង់ថា: "នែហ៊ឺន ឯកគ្គតា ចូរបាទៅអារាធនា សម្ដេចព្រះសង្ឃរាជទាំង ២ ព្រះអង្គមកជាប្រញាប់"។

ហ៊ឺនឯកគ្គតា ក៏នាំព្រះរាជឱង្ការ ទៅថ្លែងទូលសម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គថា: "បពិត្រសម្ដេចដ៏ទ្រង់នូវសីលធម៌បរិសុទ្ធព្រះបាទចិត្តរាជត្រាស់ប្រើទូលព្រះបង្គំជាខ្ញុំឱ្យមកអារាធនា សម្ដេចទាំង២ព្រះអង្គ ចូលទៅកាន់ព្រះរាជនិវេសន៍ក្នុងខណៈនេះ"។

សម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គកាលបានទទួលនិមន្តហើយ ក៏ទ្រង់ស្លៀកស្បង់ចីពរ ស្ពាយបាត្រទ្រង់យាត្រាទៅតាមមាគ៌ាទាំង ៤ ជា **លោកុត្តរមាគ៌ា** តាមលំដាប់ គឺ**សោត សកទាគាមិ អនាគាមិ អរហត្ត** ដែលជាមាគ៌ាអាចនាំព្រះបាទចិត្តរាជចេញរួចផុតពីកណ្ដាប់ដៃនៃមច្ចុរាជដោយសួស្ដីបាន។

លុះសម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គនិមន្តដោយផ្លូវធំចូលទៅ

www.budinst.gov.kh www.elibraryofcambodia.org

កាន់ព្រះរាជសំណាក់គង់លើអាសនៈដ៏សមគួរហើយ ព្រះបាទចិត្តរាជ ក៏នមស្ការបូជាគោរព ហើយត្រាស់ពិតថេរដីការថាៈ" បពិត្រសម្ដេចទាំង ២ ព្រះអង្គ! ញោមមានសេចក្ដីអផ្សុកខ្លាំងណាស់ បានជាឱ្យអារាធនា សម្ដេចជាម្ចាស់ មកដើម្បីទ្រង់ជួយដោះទុក្ខញោមក្នុងគ្រាឥឡូវនេះ ដ្បិតមច្ចុរាជចេះតែមកបៀតបៀនញោម ដោយគេប្រើមេទព័ទាំង ៤ ព្រមទាំងបរិវារឱ្យមកធ្វើបាបញោមគ្រប់ដែលញោមសាងនគរកាយពុំដែលខាន ពេលណាប្រាថ្នាឱ្យញោមនៅក្នុងអំណាចគេ បពិត្រសម្ដេចដ៏ចំរើន! ធ្វើដូម្ដេចឬ់ឱ្យញោមរួចពីកណ្ដាប់ ដៃសត្រូវនេះបាន"។

សម្ដេចព្រះមហាសង្ឃរាជទាំង២ព្រះអង្គគឺព្រះ **សមាធិន្ទ្រិយ** និងព្រះ **បញ្ញិន្ទ្រិយ** លុះបានស្ដាប់ព្រះរាជឱង្ការហើយ ក៏ប្រឹក្សាជាមួយនិងព្រះជីតុនទាំង ៣ រូប គឺព្រះ **ទុក្ខំ អនិច្ចំ អនត្តា** និងព្រះឥសីទាំង៣ រូប គឺព្រះ **បីតិ ឆន្ទា វិរិយា** ។(--------)។

សម្ដេចព្រះសង្ឃរាជ ក៏ប្រឹក្សានឹងបុរោហិត៣ រូបគឺរាជគ្រូ **ចិត្តភោ ទិចារោ អធិមោក្ខោ** តទៅទៀតថាៈ ' លោកណាយល់យ៉ាងណាខ្លះ?"។ រាជគ្រូទាំង ៣ រូបនឹករំពឹងទៅរកឃើញទោសរបស់បុគ្គលជាពួកអកុសល ហើយពិតថេរដីការថា "ទូលព្រះបង្គំ ជាខ្ញុំទាំងឡាយយល់តាមសម្ដេចទាំងអស់ "។

កាលបើដូច្នោះ សម្ដេចព្រះមហាសង្ឃរាជទាំង ២ ព្រះអង្គ ក៏ប្រឹក្សាសួរ

www.budinst.gov.kh www.elibraryofcambodia.org

ទៅឧកញ៉ា ពញ៉ា ព្រះហ្លួង ឃុន ហ្មឺន និងមហាតឡិកទាំងពួងមានឧកញ៉ា **សទ្ធា** ជាដើម "លោកអ្នកទាំងអស់នេះយល់ឃើញដូចម្តេច?"។

វរជនទាំងនោះកាលប្រឹក្សាត្រូវគ្នា កពិតថេរដីការថា "ទោសទាំងនេះមកពីបាបជនទាំង១៤ អង្គមានយុន **មោះហោ** ជាដើមជាព្រះញាតិវង្ស ព្រះបាទ**មោហ**រាជជាព្រះបិតា ព្រះនាង **លោភទេវី** ជាព្រះមាតា និងព្រះនាង **អវិជ្ជាទេវី** ជាព្រះអគ្គមហេសី បានស្ម័គ្រយកមេទព្វទាំង ៤ នាក់របស់មច្ចុរាជមាននាយ ជាតិ ជាដើម ឱ្យមកនៅក្នុងព្រះនគរកាយបានជានាំគ្នាធ្វើព្រះនគរនេះឱ្យអន្តរាយអស់"។

កាលទីប្រឹក្សា បានពិភាក្សាអស់កាលដ៏យូរយល់ឃើញព្រមគ្នាហើយ ទើបយកសេចក្តីក្រាបបង្គំទូលព្រះបាទចិត្តរាជថា"បពិត្រមហារាជ ដ៏ទ្រង់នូវព្រះសម្ភារ! ហេតុដែលនាំឱ្យខូចព្រះនគរកាយ នេះទីប្រឹក្សា បានប្រឹក្សាឃើញមូលមតិគ្នាហើយថា មកពីព្រះអង្គ ទ្រង់ជឿពាក្យបាបជនទាំង ១៤ អង្គមានយុន **មោះហោ** ជាដើមជាព្រះញាតិព្រះអង្គ ជាសត្រូវក្នុងនាំសត្រូវក្រៅមកនៅក្នុងព្រះនគរ បានជាព្រះនគរកើតអន្តរាយដូច្នេះមួយទៀតមកពីព្រះបាទ មោហរាជ ជាព្រះបិតា លោភទេវីជាព្រះមាតា និងព្រះនាង អវិជ្ជាទេវីជាព្រះអគ្គមហេសីព្រះអង្គ បានព្រមព្រៀងជាមួយ និងព្រះញាតិទាំង ១៤ អង្គទទួលយកមេទព្វព្រះបាទមច្ចុរាជទុក

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងព្រះនគរទើបពួកបច្ចាមិត្ត គេនាំគ្នាធ្វើព្រះនគរកាយរបស់ ព្រះអង្គឱ្យអន្តរាយ ដូច្នេះ រឿងនេះបើព្រះអង្គជឿស្តាប់យើងទាំងឡាយជាទីប្រឹក្សា សូមព្រះអង្គកំចាត់បង់ព្រះញាតិ វង្សទាំង ១៤ អង្គ ព្រះមាតា បិតា និងព្រះអគ្គមហេសីចេញ ទើបបច្ចាមិត្តលែងកើតទៀតបានហើយយើងទាំងពួងនឹងនាំព្រះអង្គទៅកាន់នគរកែវ ជា អមតមហានគរជាទីបរមសុខប្រាសចាកទុក្ខផុតពីកណ្តាប់ដៃនៃមច្ចុរាជ តាមព្រះរាជ បំណងបាន" ។

កាលព្រះបាទចិត្តរាជបរមក្សត្របានទ្រង់សណ្តាប់ហើយដោយទ្រង់មានព្រះរាជបំណង ចង់រួចពីកណ្តាប់ដៃនៃមច្ចុរាជ ទ្រង់ក៏ធ្វើតាមពាក្យទីប្រឹក្សាទាំងពួង មានសម្តេចព្រះសង្ឃរាជជាដើម ទើបទ្រង់តាំងមហាតឡិកម្នាក់ឈ្មោះហ្នឹន **ឯកគ្គតា** និងអគ្គសេនាម្នាក់ឈ្មោះឧកញ៉ា **ចិត្តុខុំកតា** ដែលមានចិត្តស្មោះត្រង់ និងព្រះអង្គឱ្យជាចៅក្រមជុំនុំជំរះរឿងព្រះញាតិទាំង ១៤ អង្គ មានព្រះមាតាបិតានិងព្រះអង្គមហេសីព្រម គ្នានៅទីចំពោះ ព្រះភ័ក្ត្រព្រះអង្គ ។ក្នុងសេចក្តីជុំនុំជំរះចៅក្រមសួរថា :

"នែព្រះបាទមោហរាជ ! ព្រះនាងលោភទេវី !ព្រះនាង អវិជ្ជា លោកទាំងអស់អង្គ សុទ្ធតែជាព្រះមាតា បិតា អគ្គមហេសីនៃព្រះរាជា ទាំងឃុន ១៤ អង្គក៏សុទ្ធតែជាព្រះញាតិព្រះរាជាទាំងអស់ ព្រះរាជាទ្រង់ប្រោសប្រាណទាំងអស់ លោកជានាហ្មឺនគ្រប់ -

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

គ្នា ហេតុម្តេចបានជាអស់លោកមិនគិតរក្សាព្រះអង្គ ដោយយុត្តិធម៌ បែរជាទៅក្រាបទូលណែនាំការណ៍មិនជាប្រយោជន៍ដល់ព្រះអង្គវិញ គឺនាំយកស្ត្រីបីនាក់ឱ្យចូលមកនៅក្នុងព្រះ នគរទាល់តែតេធ្វើបាប ព្រះអង្គធ្វើព្រះនគរព្រះអង្គឱ្យខូចដូច្នេះ? នៃលោកទាំងអស់គ្នា! ចូរលោកអ្នកប្រាប់ យើងជាប្រញាប់ក្នុងពេលនេះ"។

កាលនោះព្រះមាតាក្តី ព្រះបិតាក្តី ព្រះអគ្គមហេសីក្តី ព្រះញាតិទាំង ១៤ ក្តីពុំអាចឆ្លើយឱ្យការណ៍កែខ្លួនបានឡើយសឹងតែទទួលសារភាពថា" យើងខ្ញុំទាំងពួងខុសមែន មានទោសច្រើនមែន តាមតែទ្រង់ព្រះមេត្តា ប្រោសដល់យើងខ្ញុំចុះ"។

ព្រះបាទចិត្តរាជ កាលបានទ្រង់ព្រះសណ្តាប់ដូច្នេះទើបទ្រង់ព្រះរាជបញ្ជាប្រើឧកញ្ញា **សទ្ធា** ជាអគ្គសេនា ឱ្យតាំងទឹកុន្តពិធី(ពិធីសូត្រវេទមន្តបង្ក្រាបមារសេនា, សត្តពោជ្ឈង្គ)ឡើង។

គ្រានោះហេតុតែវាសនាបារមី ព្រះបាទចិត្តរាជ ចាស់ក្លា និងដោយសារឫទ្ធិឥសីទាំង ៣ រូបគឺព្រះ **បីតិឆន្ទា វិរិយោ** លោកសូត្រសែក ព្រះវេទមន្តឡើងព្រះខាន់ជ័យស្រីទាំង ៣ ក៏កើតឡើងកណ្តាលទឹកុន្តពិធីនោះ ទើបព្រះឥសីទាំងឡាយថ្វាយពរថា"កាលនេះជាកាលគួរ ដែលព្រះអង្គ ទ្រង់យាងចូលទៅកាន់ទឹកុន្តពិធីហើយ សូមព្រះអង្គ ទាញយកព្រះខាន់ជ័យស្រីទាំង ៣ អំពីទឹកុន្តពិធីនោះចុះ"។

ព្រះបាទចិត្តរាជព្រះអង្គលូកព្រះហស្ត ទៅទាញយកព្រះខាន់ជ័យស្រីទាំង

www.budinst.gov.kh www.elibraryofcambodia.org

៣ អំពីគំនរភ្លើងនៃកុន្តពិធីសូម្បីនឹងបានក្ដៅ ព្រះហស្ថបន្តិចបន្តួចក៏ទេ។ឯព្រះខាន់ជ័យស្រីទាំង ៣ នោះឈ្មោះ ១ **គនខ្គប្បហារ** មានដងប្រាក់អាចញុំញីសត្រូវបានដោយអន្លើ១។ ២ **ចិត្តម្ភនប្បហារ** មានដងមាស អាចសង្កត់សង្កិនសត្រូវដូចថ្មសង្កត់ស្មៅមិនឱ្យកម្រើកបាន ។ ៣ **សមុទ្ធេទប្បហារ** មានដងវិចិត្រដូចកែវ ៧ប្រការ អាចប្រហារ សិរសារាជ សត្រូវទាំងឡាយឱ្យដាច់ ដូចត្នោតកំបុតក ។

ព្រះបាទចិត្តរាជ ទ្រង់ចាប់ព្រះខាន់ជ័យស្រីទាំងនោះ ព្រះរាជទានទៅអគ្គសេនាឈ្មោះឧកញ៉ា **ចិត្តបស្សទ្ធិ** ដែលមានចិត្តថ្លាដូចកែវឱ្យជារាជតំណាងដោយទ្រង់ព្រះរាជបញ្ជាថា "ចូរអ្នកឯងសំលាប់ព្រះបាទ **មោហរាជ** ជាបិតាយើងដែលនាំឱ្យយើង វង្វេង. ព្រះនាង **លោភទេវី** ជាមាតា ដែលនាំឱ្យយើងលោភផឥតខ្មាស.ព្រះនាង **អទិជ្ជាទេវី** ជាអគ្គមហេសីយើង ដែលនាំឱ្យ យើងងងឹតមុខជ្រប់ទៅតាមវាហើយចូរឯងសម្លាប់ពួកបាបជន ទាំង ១៤ នាក់ដែលជាព្រះញាតិវង្សយើង ដ្បិតអ្នកអស់នេះវាឱ្យសត្រូវខាងក្រៅចូលមកនៅក្នុងស្រុកយើង ឱ្យសត្រូវធ្វើឱ្យខូចព្រះនគរយើង១ ត្រូវតែសម្លាប់វាឱ្យអស់កុំឱ្យសល់ម្នាក់" ។

ឯឧកញ៉ា **ចិត្តបស្សទ្ធិ** កាលទទួលព្រះរាជបញ្ជា ហើយក៏ប្រហាជីវិតជនអំបាលនោះគ្មានសល់ម្នាក់ ដោយព្រះខាន់ឈ្មោះ សមុច្ឆេទប្បហារ ។

អស់លោកអ្នកសណ្ដាប់រឿងនេះ សូមកុំយល់ថា ព្រះបាទចិត្តរាជមាន រូប

www.budinst.gov.kh www.elibraryofcambodia.org

ជាមនុស្ស ប្រើឱ្យគេសម្លាប់ មាតាបិតា មានរូបជាមនុស្សនោះឡើយ មិនមែនដូច្នេះទេ គឺ ចិត្តសម្លាប់ ចេតសិក ដែលទុកដូចជាមាតា បិតា ដោយរឿងនេះ លោកលើកយកធម្មាធិដ្ឋានមកតែងជាបុគ្គលាធិដ្ឋានជាន័យ ប្រៀបធៀប ដើម្បីឱ្យអ្នកមាន ប្រាជ្ញាតិចស្តាប់បានដោយងាយ ។ ព្រះបាទចិត្តរាជ ក៏គឺដួងចិត្តយើងគេទាំងពួងទាំងឡាយ នគរកាយ ក៏គឺរូប កាយយើងគេទាំងពួងនេះឯង ទាំងព្រះមាតាបិតា ព្រះអគ្គមហេសី ព្រះញាតិ ១៤ អង្គ និងអគ្គសេនា ១៩ នាក់ ក៏សុទ្ធតែជាកុសលាកុសលចេតសិកទាំងអស់ ។

អត្ថបទប្រៀបធៀប ដែលលោកលើកមកសំដែងនេះ ត្រូវគ្នានឹងអត្ថបទប្រៀបធៀបដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងទុកក្នុងគម្ពីរ ខុទ្ទកនិកាយធម្មបទ ត្រង់បកិណ្ណកវគ្គថា :

មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ

រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។

ជនណាសម្លាប់មាតា គឺ តណ្ហា ,សម្លាប់បិតា គឺ អស្មិមានៈ, សម្លាប់ក្សត្រទាំងពីរជាស្តេច គឺ សស្សតទិដ្ឋិ និង ឧច្ឆេទទិដ្ឋិ , សម្លាប់នាយស្មៀន គឺនន្ទិរាគ (អាយតនៈ) ដែលវាលាតត្រដាងពាសរដ្ឋ ពាសដែន .ជនទាំងនោះ រមែងបាន ជាព្រះខីណាស្រព អស់ទុក្ខភ័យដោយពិត ។

www.budinst.gov.kh www.elibraryofcambodia.org

កាលឧកញ៉ា ចិត្តបស្សទ្ធិ ប្រហារជីវិតជនទាំងអស់ ហើយសម្តេចព្រះមហាសង្ឃរាជ ២ព្រះអង្គ.ព្រះជីតុន ៣រូប. ព្រះឥសី ៣រូប. បុរោហិត ៣រូប មហាតឡិក ៧រូប. និងអគ្គសេនា ១៩នាក់ ក៏ប្រារព្ធនឹងសុំយាងព្រះបាទចិត្តរាជចេញចាកនគរកាយ ។

គ្រានោះព្រះសម្តេចព្រះមហាសង្ឃរាជ ថ្វាយព្រះរាជពរថា "បពិត្រមហារាជ ដ៏ទ្រង់នូវព្រះបារមី ! សូមព្រះអង្គយាងចុះមក អាត្មាភាពទាំងឡាយ នឹងនាំព្រះអង្គទៅកាន់ព្រះនគរកែវ ជាស្រុករបស់ព្រះអរិយបុគ្គល អាត្មាភាពជាមគ្គុទេសក៏ នឹងនាំផ្លូវព្រះអង្គ ទៅក្នុងកាលឥឡូវនេះ" ។

ឯព្រះបាទចិត្តរាជកាលសម្តេចសង្ឃទាំងពីរអង្គ គឺព្រះសមាធិន្ទ្រិយ ព្រះបញ្ញិន្ទ្រិយបានណែនាំ ( ពោលគឺ **សមាធិនិងបញ្ញា** បានកើតក្នុងចិត្តឃើញនូវសភាវធម៌ទាំងពួងតាមពិត ) ហើយទើបព្រះអង្គទ្រង់ តាក់តែង ព្រះកាយដោយគ្រឿងទិព្វរតន៍ ភូសា សៃ សយ សង្វារ ស្ទួរង កង ព្រះប៉ូរាក់ ស្ពាប់ ព្រះឱរ្យប្រកបទៅដោយ កញ្ចង់ពិសេស ពាលគឺព្រះពោធិបក្ខិយធម៌ ៣៧ ប្រការគឺ **សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ** ៧ និង **អដ្ឋង្គិកមគ្គ** ៨ ជាគ្រឿងអលង្ការដ៏ល្អរុងរឿង ហើយទ្រង់ពាក់ នូវព្រះទម្រង់គ្រប់ ម្រាម ទាំង ១០ ពោលគឺសិក្ខាបទ ១០ និងទ្រង់នូវមហាមកុដ

www.budinst.gov.kh www.elibraryofcambodia.org

៧ និងទ្រង់នូវគ្រោះពេជ្រសម្រាប់ព្រះតេជានុភាព ពោលគឺព្រហ្មវិហារធម៌ ៤ ប្រការគឺ **មេត្តា ករុណា មុទិតាឧបេក្ខា** ហើយទ្រង់នូវព្រះខគ្គាវុធពោល គឺ **សម្មប្បធានប្បហារ** ដែលអាច កាប់ កាត់កំចាត់បង់សត្រូវទាំងពួងពោលគឺអកុសលទាំងអស់បាន ។លុះទ្រង់គ្រឿងអលង្ការស្រេចហើយទើបទ្រង់យាងឡើងប្រថាប់លើធម្មរថ ពោលគឺព្រះសទ្ធម្ម ៨៤០០០ ព្រះធម្មក្ខន្ធហើយក៏ទ្រង់និសីទនាកា លើរតនបល្ល័ង្កព្រះទីនាំង ដ៏ប្រកបដោយកែវ ៩ ប្រការគឺ ព្រះ **នពលោកុត្តរ៩ គឺ មគ្គ ៤ ផល ៤ និព្វាន១** ។

ឯធម្មរថនោះសឹងទឹមដោយសេះសន្ធវជាតិអាជានេយ្យ ៤ គឺចតុប្បារិសុទសីលទាំង ៤ គឺ **បាតិមោក្ខសំវរសីល ឥន្រ្ទីយសំវរសីល អាជីវបារិសុទ្ធ-សីល បច្ចយសន្និស្សិតសីល** ។

ធម្មអាជានេយ្យទាំងបួននេះ ក៏ទាញនូវព្រះធម្មរថឲ្យអណ្តែតត្រសែតលើនភាល័យ ហើយព្រះបាទចិត្តរាជបរមក្សត្រ ព្រះអង្គប្រកបដោយ **ឥទ្ធិវិធ** ៤ ប្រការពោលគឺ **ឆន្ទិទ្ធិបាទ**(ឫទ្ធិសម្រេចដោយសេចក្តីប្រាថ្នា)**វិរិយទ្ធិបាទ**(ឫទ្ធិសម្រេចដោយសេចក្តីព្យាយាម) **ចិត្តិទ្ធិបាទ** (ឫទ្ធិសម្រេចដោយចិត្ត)**វិមំសិទ្ធិបាទ**(ឫទ្ធិសម្រេចដោយបញ្ញា) ហើយទ្រង់បានត្រាស់ដឹងនូវព្រះញាណទាំង ៤ប្រការគឺៈ**បុព្វេនិវាសញ្ញាណ ខេសាវជ្ជញ្ញាណ អនាវរណញ្ញាណ** និង **សព្វញ្ញុតញ្ញាណ** ។

www.budinst.gov.kh www.elibraryofcambodia.org

វរជនទាំងឡាយមានសម្តេចព្រះមហាសង្ឃរាជ ជាមគ្គុទេសក៏បាននាំព្រះបាទចិត្តរាជ ទៅតាមមាគ៌ាទាំង ៤ គឺ **សោត សកទាគាមិ អនាគាមិ អរហត្ត** ជាផ្លូវលោកកុត្តរ របស់ព្រះអរិយបុគ្គលទាំងពួងពីបុរាណ ។ ព្រះបាទ ចិត្តរាជក៏អណ្តែតត្រសែតលឿន លើវេហាស៍ កណ្តាលហ្វូងយោធាវេហ៍ពលបានទៅដល់ព្រះនគរកែវ ជាស្រុកក្សេមក្សាន្ត ប្រាសចាកទុកពោលគឺអមតៈមហានគរនិព្វានជាថានបរមសុខប្រសើរផុតពីកណ្តាប់ដៃនៃមច្ចុរាជ គឺសេចក្តីស្លាប់មច្ចុរាជមិនអាចតាមបំផ្លាញព្រះអង្គដូចពីមុនបានដោយហេតុព្រះអង្គយាងចូលស៊ប់ទៅក្នុងព្រះនគរកែវព្រះនិព្វាន ដ៏មានកំពែងកែវ ៧ ជាន់ជិតជុំមាំមួនក្រៃពេកជាព្រះនគរដ៏ប្រាសចាកទុក្ខទាំង៤កង គឺ **ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ** ឥតជិតដល់យល់ឃើញឡើយ ។

ព្រះបាទចិត្តរាជបរមក្សត្រ ព្រះអង្គបានគង់នៅជាបរមសុខក្នុងឋាន ព្រះនិព្វានដូចបានពណ៌នាមក ។ធម្មកថានេះ ពណ៌នាតាមលំអានបរមត្ថធម៌ ដែលព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់សម្តែងអំពីកាយនិងចិត្ត ជាផ្លូវធម៌ធៀបផ្លូវលោកដើម្បីពន្យល់សាធុជន ដែលបានអានបានស្តាប់អោយយល់ច្បាស់នូវទោសនៃជាតិ ជរា ព្យាធិ មរណៈ ដែលនាំសត្វអោយហែលវិលវល់ ប្លេងប្លោងនៅក្នុងសមុទ្រនៃវដ្តសង្សារ ។

www.budinst.gov.kh www.elibraryofcambodia.org

សាធុជនដែលបានអាន បានស្តាប់នូវស័ព្ទព្រះធម៌នេះ គប្បីគួចកត់កំណត់ចាំអោយជាក់ច្បាស់គ្រប់ន័យត្រង់ណាដែលធម្មកថានេះពោលសង្ខេប គឺគ្រាន់តែរាប់ឈ្មោះ ពុំបានប្រែ ពុំបានអធិប្បាយ ឬអធិប្បាយដោយខ្លីៗ បើស្តាប់សេចក្តីពុំបានគប្បីសាកសួរប្រឹក្សា ដល់បណ្ឌិតបរមត្ថសាស្ត្រ ដែលឆ្លៀវឆ្លាសក្នុងបរមត្ថធម៌ ឱ្យលោកពន្យល់តទៅ ។ សូមសេចក្តីសុខ សេចក្តីចម្រើនកើតមានដល់អ្នកអាន អ្នកស្តាប់ទាំងឡាយ ។

**ភិក្ខុ ហម** ចារចប់ថ្ងៃ សុក្រ ៩ កើត ខែ បុស្ស ឆ្នាំវក ចិត្វាស័ក ព.ស ២៥៣៦ ។ យាយឧបាសិកា **ជុន** ព្រមទាំងបត្រាបុត្រី ទាំងអស់មូលមតិគ្នាសាងសស្ត្រា នគរកាយនេះ ទុក តព្រះសាសនាឱ្យគ្រប់ ៥០០០ព្រះវស្សា សូមប្រាថ្នា សម្បត្តិ ៣ ប្រការ គឺ សម្បត្តិ មនុស្ស សម្បត្តិទេវតា និង សម្បត្តិព្រះនិព្វាន ជាទីអវសានជាតិ ទៅហោង ។

www.budinst.gov.kh www.elibraryofcambodia.org



សាងពុទ្ធ ពោធិញ្ញាណោ

វត្តឧណ្ណាលោម

www.budinst.gov.kh www.elibraryofcambodia.org

ភ្នំពេញ
ការផ្សាយចេញពីខុទ្ទកាល័យ សម្តេចព្រះសង្ឃរាជ
ព.ស ២៥៤៩ - គ.ស ២០០៥
www.budinst.gov.kh www.elibraryofcambodia.org